# ផ្សាយមេត្តាឲ្យខ្លួនឯង

*(បទពាក្យ ៧)*

**អហំ សុខិតោ ហោមិ និទ្ទុក្ខោ ហោមិ អវេរោ ហោមិ អព្យាបជ្ឈោ ហោមិ អនីឃោ ហោមិ អរោគោ ហោមិ សុខីអត្តានំ បរិហរាមិ ។**

*ខ្ញុំសូមតាំងចិត្តអធិដ្ឋាន សូមឲ្យខ្ញុំបានជួបសុខសួស្តី*
*ចម្រើនរុងរឿងល្អប្រពៃ នៅក្នុងលោកីយ៍តរៀងទៅ ។*
*សូមកុំឲ្យជួបនូវកងទុក្ខ ដែលជាប្រមុខនាំអាស្រូវ*
*នាំឲ្យរាំងស្ទះការរស់នៅ នាំឲ្យរាំងផ្លូវត្រូវប្រតិបត្តិ ។*
*សូមកុំឲ្យមានពៀរវេរា នឹងមនុស្សផងគ្នាព្រមទាំងសត្វ*
*ព្រមទាំងទេវតាខ្មោចព្រៃស្ងាត់ ខ្មោចព្រៃចល័តខ្មោចជ្រោះភ្នំ ។*
*សូមឲ្យចិត្តខ្ញុំស្រឡាញ់ស្មោះ មនុស្សសត្វទាំងអស់តូចឬធំ*
*ខ្ពស់ទាបខ្មៅស ធាត់ឬស្គម សូមរស់សុខព្រម ៗ គ្រួសារ ។*
*ប្រសិនបើចិត្តខ្ញុំបៀតបៀន សូមកុំឲ្យមានទៀតឡើយណា*
*មានតែចិត្តស ល្អភ្លឺថ្លា លើសក្បាច់រចនាពេជ្រចរណៃ ។*
*សូមឲ្យចិត្តខ្ញុំត្រជាក់ពិត ដូចទឹកអម្រិតព្រះជិនស្រី*
*ព្រះអង្គជាស្តេចលើភពបី យើងជនប្រុសស្រីតែងបូជា ។*
*សូមឲ្យខ្ញុំប្រាសចាករោគភ័យ រោគកាចចង្រៃឆ្ងាយអង្គា*

*ឆ្ងាយចិត្តខ្ញុំផងគ្រប់វេលា គ្រប់គ្រាសុខភាពខ្ញុំមាំមួន ។*
*ខ្ញុំសូមប្រាថ្នានូវក្តីសុខ កុំឲ្យក្តីទុក្ខកើតផ្ទួន ៗ*
*ទោះបីមានក្នុងកាយចិត្តខ្លួន សូមឃ្លាតរួសរាន់ទាន់ចិត្តហោង ។l*

# ផ្សាយមេត្តាទូទៅ

*(បទពាក្យ ៧)*

**សព្វេ សត្តា អវេរា ហោន្តុ អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ សុខី អត្តានំ បរិហរន្តុ សុខិតា ហោន្តុ ញាតិយោ ។**

*សូមឲ្យសព្វសត្វនៅក្នុងលោក ជាសត្វមានជោគមានវាសនា*
*ជាសត្វជួបជុំក្រុមគ្រួសារ ឬរស់ឯកាតាមធម្មជាតិ ។*
*សូមឲ្យសព្វសត្វទាំងឡាយនោះ រស់នៅក្នុងឈ្មោះសត្វល្អស្អាត*
*គឺសុខចម្រើនកុំបីឃ្លាត សុខហើយសុខទៀតសុខរហូត ។*
*សូមឲ្យជាសត្វប្រាសចាកពៀរ រស់នៅនឹងគ្នាយ៉ាងស្លូតបូត*
*ជាសត្វមានចិត្តមិនងាយក្រោធ មិនចេះច្រឡោតលោតចងពៀរ ។*
*សូមឲ្យជាសត្វរស់បានសុខ ប្រាសចាកទុក្ខសោកគ្រប់ៗ គ្នា*
*ទោះបីរោគក្មេងរោគជរា រោគក្នុងអង្គា ឬក្នុងចិត្ត ។*

សូមឲ្យរលាយរលត់ទៅ    កុំបីមាននៅនាំរួបរិត
រុករានទន្ទ្រានរូបកាយចិត្ត    ឲ្យបង់ជីវិតព្រោះរោគា ។
សូមឲ្យជាសត្វចេះរក្សា    ចេះជួយអាត្មា និងគ្គីគ្គា
ដើម្បីបានសុខគ្រប់វេលា    គ្រប់គ្គាត្រូវមានធម៌សាមគ្គី ។
សូមឲ្យញាតិខ្ញុំផងទាំងឡាយ    បានសុខសប្បាយរស់មូលមី
រស់ក្នុងកិច្ចការល្អទាំងពីរ    ដែលព្រះមុនីសម្ដែងទុក ។
ទី ១ ការងារក្នុងលោកនេះ    ទី ២ ការងារលោកខាងមុខ
សូមឲ្យញាតិខ្ញុំមានក្ដីសុខ    ប្រាសចាកទុក្ខសោករោគចង្រៃ។
បើសិនញាតិខ្ញុំបានសុខហើយ    ឱម្ចាស់ថ្លៃហ្អើយខ្ញុំអរក្រៃ
សូមឲ្យញាតិខ្ញុំទាំងប្រុសស្រី    បានសុខធំក្រៃ គឺព្រះនិព្វាន ។



# អានិសង្សនៃការផ្សាយមេត្តា ១១ យ៉ាង

១. សុខំ សុបតិ *ដេកលក់ក៏ជាសុខ ។*

២. សុខំ បដិពុជ្ឈតិ *ក្រោកឡើងក៏ជាសុខ ។*

៣. ន បាបកំ សុបិនំ បស្សតិ *មិនយល់សប្តិ៍អាក្រក់ ។*

៤. មនុស្សានំ បិយោ ហោតិ

*ជាទីស្រឡាញ់នៃមនុស្សទាំងឡាយ ។*

៥. អមនុស្សានំ បិយោ ហោតិ

*ជាទីស្រឡាញ់នៃពួកអមនុស្សទាំងឡាយ ។*

៦. ទេវតា រក្ខន្តិ *ទេវតារមែងថែរក្សាការពារ ។*

៧. នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ

*ភ្លើងក្តី ថ្នាំពិសក្តី ស្រ្តាវុធក្តីធ្វើអ្វីយើងមិនបានឡើយ ។*

៨. តុវតំ ចិត្តំ សមាធិយតិ *ចិត្តរមែងជាសមាធិយ៉ាងឆាប់រហ័ស ។*

៩. មុខវណ្ណោ វិប្បសីទតិ *ស្បែកមុខមានពន្លឺភ្លឺថ្លា ។*

១០. អសម្មុឡ្ហោ *ជាអ្នកមិនវង្វេងក្នុងការធ្វើកាលកិរិយា ។*

១១. ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ

*ដរាបណាមិនទាន់បានគុណវិសេសថ្នាក់ខ្ពស់*

*ដរាបនោះនឹងមិនទៅកើតនៅព្រហ្មលោកឡើយ ។*

## ផលានិសង្សសុចរិត *(ពាក្យ ៧)*

**ធម្មោ ហវេ រក្ខតិ ធម្មចារឹ ធម្មោ សុចិណ្ណោ សុខមាវហាតិ**

**ឯសានិសំសោ ធម្មេ សុចិណ្ណេ ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។**

*ធម៌សុចរិត តាមការណ៍ពិត តែងរក្សា*
*នូវជនណា ដែលប្រព្រឹត្ត នូវធម៌នោះ,*
*ធម៌សុចរិត ដែលបណ្ឌិត សន្សំស្មោះ,*
*ពុំដែលផ្សោះ តែងនាំសុខ មកផ្តល់ឲ្យ ។*
*នេះគឺជា អានិសង្ស ការផ្ចង់ចិត្ត,*
*ខំប្រព្រឹត្ត សន្សំធម៌ ពុំដែលធ្លោយ,*
*វីបុគ្គល អ្នកប្រព្រឹត្ត- ធម៌ពុំខ្សោយ*
*លុះជាតិក្រោយ តែងបានសោយ សុខសួគ៌ា ។*
*រឿងពីព្រេង ព្រះសម្តែង ប្រាប់បញ្ជាក់,*
*ថាមានអ្នក ប្រព្រឹត្តធម៌ សុចរិតា,*
*ពូជធម៌បាល ឥតសមានសល់ រូបជនណា,*
*ទាំងអស់គ្នា សុទ្ធតែមាន អាយុវែង ។*
*ជនណាបាន ប្រព្រឹត្តធម៌ នេះទៀងទាត់,*
*ពុំដែលភ្លាត់ តែងរស់នៅ យូរអង្វែង,*
*ដូចភាសិត ដែព្រះពុទ្ធ ទ្រង់សម្តែង,*
*ជននោះឯង តែងបានសុខ ប្រសើរហោង ៕*